ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

-លេខ ២៦០ (ឋ)
-ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨
-សំណុំរឿងព្រហ្មទណ្ឌលេខ ៦២១
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥
-សំណុំរឿងស៊ើបសួរលេខ ២១១៥
ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥
-សំណុំរឿងជំនុំជម្រះលេខ ៤១៣២
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង ២ និង ០០ នាទីរសៀល នៅសាលសវនាការទី៤ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៦២១ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥

ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted]សុភី ហៅ អាស្រី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ បើកហាងរ៉ិតសក់ ទីកន្លែងកំណើតនៅភូមិត្រើយស្លា ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] មានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "ស" ប្ដីឈ្មោះ [redacted] "រ" មានកូន ០៥នាក់ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ ឆបោក ប្រព្រឹត្តនៅចំណុចច្បា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងអោយផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ទឹម ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

-ដោយមានមេធាវី [redacted]លីន , [redacted]ផ្កា , [redacted]ទី , [redacted] ផានី , [redacted]តារា ជាមេធាវីតំណាងដោយអាណត្តិ និងការពារសិទ្ធិឲ្យដើមបណ្ដឹង ។

## <u>អង្គហេតុនៃរឿងមានដូចតទៅ</u>

កាលនៅអំឡុងខែវិច្ឆិកា ឆ្នាំ២០១៣ ឈ្មោះ[redacted] សុភី ភេទស្រី អាយុ៥២ឆ្នាំ បានប្រើឧបាយកលទុច្ចរិត ដោយអះអាងក្លែងបន្លំថា ខ្លួនជាម្ចាស់កម្មសិទ្ធិដីមួយកន្លែង ទំហំ ១៩៨ម៉ែត្រការ៉េ ស្ថិតនៅភូមិច្បា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ហើយតាមរយៈការអះអាងក្លែងបន្លំនេះ បានធ្វើឲ្យឈ្មោះ [redacted] វ៉ាន់ណេត មានការជឿជាក់ ក៏បានទិញយកដីនោះក្នុងតម្លៃមួយម៉ែត្រការ៉េ ១០៨$ បន្ទាប់មកឈ្មោះ[redacted]វ៉ាន់ណេត បានចាក់ដីចំនួន ២លើក ធ្វើរបង តបណ្ដាញទឹក

និងឲ្យមើលដីនោះ អស់ប្រាក់ប្រមាណ ៦,០០០$ ។ លុះមកដល់ខែមករា ឆ្នាំ២០១៥ ស្រាប់តែមានឈ្មោះ [redacted] ម៉េង បាន កាន់កាប់ដោយមិនដឹងមកអះអាងថា ជាដីរបស់គាត់ ហើយពេលនោះរាជធានីសង្កាត់ និងខណ្ឌ ក៏បានទទួលស្គាល់ថា ដីខាងលើពិតជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ម៉េង ប្រាកដមែន ។

-បានឃើញ ពាក្យបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ឈ្មោះ [redacted]ទីម តំណាងឲ្យឈ្មោះ [redacted] វ៉ាន់ណេត ។

-បានឃើញ ដីកាសម្រេចស្ដាពលេខ ៣៣៩០ រ.ឃ.ត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់លោក [redacted] ណា តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៨៦ "ណា" ជ.ជ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់លោក [redacted] នៅក្រុមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## <u>នាពេលសវនាការ</u>

-ក្រឡាបញ្ជីរកត់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ រាស្រី ដែលបានឆ្លើយថា៖ ខ្លួនសុំបដិសេធ នូវការប្ដឹងចោទប្រកាន់របស់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងស្រុង ព្រោះដីខាងលើនេះ គឺជាដីរបស់ខ្លួនពិតប្រាកដមែន ដីនេះ ខ្លួនទិញពីឈ្មោះ [redacted]ចរិយា ក្នុងឆ្នាំ២០០៥ ក្នុងតម្លៃ ២០,០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ដោយមានឯកសារត្រឹមត្រូវ ហើយដីនេះខ្លួនបានកាន់កាប់អស់រយៈពេល ៨ឆ្នាំមកហើយ។ នៅក្នុងឆ្នាំ២០១៣ ខ្លួនបានលក់ដីនេះឲ្យទៅឈ្មោះ [redacted] វ៉ាន់ណេត ក្នុងតម្លៃ ២១,០០០$ (ពីរម៉ឺនមួយពាន់ដុល្លារអាមេរិក) ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងត្រឹមត្រូវ និងមានការបញ្ជាក់ពីអាជ្ញាធរសង្កាត់ដង្កោទៀតផង។ ក្រោយពេលលក់រួចមកអ្នកទិញបាន ចាក់ដី និងធ្វើរបងនៅលើដីនោះ ហើយក៏ពុំឃើញមានគតិយជន មកអះអាងថាដីនេះជាកម្មសិទ្ធិរបស់គាត់ឡើយ លុះ បានប្រហែល ១ឆ្នាំក្រោយមក ក៏មានឈ្មោះ [redacted]ម៉េង មកអះអាងថាដីនេះជាកម្មសិទ្ធិរបស់គាត់ ហើយអាជ្ញាធរខណ្ឌ ក៏បានហៅខ្លួនមកចរចារដើម្បីឲ្យខ្លួនប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted] ម៉េង តែមិនមានឯកសារណាមួយបញ្ជាក់ថាជាដី របស់ឈ្មោះ [redacted] ម៉េង នោះទេ ។ អាជ្ញាធរខណ្ឌដង្កោ បានឲ្យខ្លួនប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted]ម៉េង ព្រោះគេជាអ្នក រស់នៅជាមួយសម្ដេច [redacted] ពេលឮដូច្នេះ ខ្លួនភ័យខ្លាចក៏ប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted]ម៉េង និងមិនហ៊ានសួរ ទាំងរកលិខិតស្នាមបញ្ជាក់អ្វីឡើយ។

-ក្រឡាបញ្ជីរកត់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]ទីម ដែលបានឆ្លើយថា៖ កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ ២០១៣ ឈ្មោះ [redacted] សុភី បានលក់ដីមួយកន្លែងទំហំ ១៩៨ម៉ែត្រការ៉េ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានី ភ្នំពេញ មកឲ្យខ្លួនក្នុងតម្លៃមួយម៉ែត្រការ៉េ ១០៥$ ពេលនោះគាត់បានបង្ហាញឯកសារ និងអះអាងថាដីខាងលើនេះ គឺជា ដីរបស់គាត់ ហើយអាជ្ញាធរក៏បានចុះវាស់វែងបង្ហាញព្រំប្រទល់ និងបោះបង្គោលព្រំទៀតផង បន្ទាប់មកអាជ្ញាធរក៏បាន បញ្ជាក់ថា ដីនេះពិតជាដីរបស់ឈ្មោះ [redacted]សុភី ប្រាកដមែន ។ ដោយមានការជឿទុកចិត្ត ខ្លួនក៏បានទិញដីនោះ ហើយ ឈ្មោះ [redacted]សុភី ក៏បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងកិច្ចសន្យា ព្រមទាំងលិខិតធានាអះអាងទៀតផង ។ លុះដល់ឆ្នាំ២០១៥ ស្រាប់តែមានឈ្មោះ [redacted] ម៉េង បានមកអះអាងថាដីដែលខ្លួនទិញនោះ គឺជាដីរបស់គាត់ ដោយបាន បង្ហាញប័ណ្ណកម្មសិទ្ធិករលើដីនោះដែរ ពេលនោះឈ្មោះ [redacted] សុភី ក៏បានព្រមព្រៀងទទួលស្គាល់ថា ដីដែលគាត់លក់មក



Scanned with CamScanner

[illegible] ឈ្មោះ [redacted] ម៉េង ហើយកាត់ព្រមសម្រួលនឹងការព្រមផ្ទេរទិញដីឲ្យមកខ្លួនវិញដែរ តែក្រោយមក [illegible] ឈ្មោះ [redacted] សុភី បែរជាមកដាក់ពាក្យប្តឹងប្រឆាំងឲ្យមកខ្លួនវិញទៀត។ ចំពោះដីនេះ ខ្លួនបានទិញដីធ្វើ [illegible] ចំនួនប្រហែល ៦,០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក)។

ក្រុមប្រឹក្សាមានចម្លើយទៅក្ខ្សិនឈ្មោះ [redacted] មិត្តា ដែលបានឆ្លើយថា៖ ឈ្មោះ [illegible] តំណាងឲ្យឈ្មោះ ហោក រ៉ាំងណោត បានឲ្យទៅខ្លួនប្រាប់ឈ្មោះ [redacted] សុភី មានដីមួយកន្លែងទំហំ ១៩៨ម៉ែត្រការ៉េ ស្ថិតនៅភូមិថ្មា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលដីនេះពីមុនឡើយ នៅក្នុងឆ្នាំ២០០៨ ឈ្មោះ [redacted] រ៉ែលា បានផ្ទេរសិទ្ធិកាន់កាប់មកឲ្យប្រពន្ធខ្លួន ហើយនៅក្នុងឆ្នាំ២០១៣ ខ្លួនក៏បានផ្ទេរសិទ្ធិទៅឲ្យប្រពន្ធខ្លួន ហើយប្រពន្ធខ្លួនក៏បានលក់ដីនោះឲ្យទៅឈ្មោះ [redacted] រ៉ាំងណោត និងបានផ្ទេរសិទ្ធិត្រឹមត្រូវតាមច្បាប់។ ក្រោយមកនៅឆ្នាំ២០១៨ ក៏កើតឈ្មោះ [redacted] ម៉េង បានមកអះអាងថាដីនេះជាដីរបស់គាត់ ហើយប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះដីកាលនោះ ខ្លួន និងប្រពន្ធ ខ្លួនសុខចិត្តសងប្រាក់ទៅឲ្យអ្នកទិញឈ្មោះ [redacted] រ៉ាំងណោត វិញទៅតាមតម្លៃទីផ្សារជាក់ស្តែង។

ក្រុមប្រឹក្សាមានចម្លើយទៅក្ខ្សិនឈ្មោះ [redacted] សារឿន ដែលបានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០១៣ ឈ្មោះ [redacted] សុភី បានលក់ដីឲ្យទៅឈ្មោះ [redacted] រ៉ាំងណោត និងបានធ្វើលិខិតផ្ទេរសិទ្ធិនៅចំពោះមុខខ្លួនដែលជាចៅសង្កាត់ដង្កោ ។ ខ្លួនមិនបានចុះទៅពិនិត្យមើលទីតាំងដីនេះទេ ប៉ុន្តែឃើញមានលិខិតកំណត់ហេតុមេភូមិឈ្មោះ [redacted] ភ្ជាប់មកជាមួយ ដោយផ្អែកលើលិខិតទាំងនេះ ខ្លួនក៏បានបញ្ជាក់ទៅលើលិខិតផ្ទេរសិទ្ធិនោះតែម្តង។ ក្រោយមកក៏កើតពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ម៉េង ថាឈ្មោះ [redacted] សុភី បានយកដីដែលជារបស់គាត់ទៅលក់ ហើយគាត់ក៏បានបង្ហាញលិខិតបញ្ជាក់កម្មសិទ្ធិលើដីនោះ ទើបខ្លួនដឹងថាដីនោះមិនមែនជារបស់ឈ្មោះ [redacted] មិត្តា និងឈ្មោះ [redacted] សុភី ទេ ។ ក្រោយមកខាងអាជ្ញាធរសង្កាត់ និងខណ្ឌដង្កោ បានហៅពួកគេមកសាកសួរ ហើយពួកគេក៏បានសារភាពថាច្រឡំដីរបស់ឈ្មោះ [redacted] ម៉េង ស្មានថាជាដីរបស់ខ្លួន ហើយគេក៏បានយល់ព្រមប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted] ម៉េង កាន់កាប់វិញដែរ ហើយគេបានសន្យាថានឹងធានាដោះស្រាយជាមួយអ្នកទិញបន្តទៀតឲ្យបានចប់សព្វគ្រប់ តែការដោះស្រាយជាមួយអ្នកទិញឈ្មោះ [redacted] រ៉ាំងណោត ចរចារក្លាមិនត្រូវគ្នាទេ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណី

**-លោកមេធាវី [redacted] តារា និងលោក មេធាវី [redacted] ដារី ជាមេធាវីតំណាងដោយអាណត្តិ និងការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា៖**

**១.អង្គហេតុ**

នៅក្នុងអំឡុង ខែវិច្ឆិកា ឆ្នាំ២០១៣ ឈ្មោះ [redacted] សុភី បានលក់ដីមួយកន្លែងទំហំ ១៩៨ម² ស្ថិតនៅភូមិថ្មា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឲ្យមកឈ្មោះ [redacted] រ៉ាំងណោត ក្នុងតម្លៃ ១០៨ដុល្លារអាមេរិក ពេលនោះឈ្មោះ [redacted] សុភី បានបង្ហាញឯកសារ និងអះអាងថាដីខាងលើនេះគឺជាដីរបស់ខ្លួនពិតប្រាកដ ដោយមានការជឿជាក់ទើបឈ្មោះ [redacted] រ៉ាំងណោត សម្រេចចិត្តទិញដីនោះពីឈ្មោះ [redacted] សុភី ដោយឯកភាពធ្វើកិច្ចសន្យាទិញលក់ដីនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ ក្រោយពីបានធ្វើការទូទាត់ប្រាក់ចប់សព្វគ្រប់ឈ្មោះ [redacted] សុភី ក៏បានធ្វើការផ្ទេរកម្មសិទ្ធិមកឲ្យឈ្មោះ [redacted] រ៉ាំងណោត តាមរយៈលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១០០១៩/១៣ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣



Scanned with CamScanner

អោយគាត់ប្រគល់ទេ។ បន្ទាប់ពីទិញដីរួចឈ្មោះ [redacted] វ៉ាន់ណេត ក៏បានចាក់ដីបំពេញពីរលើក ធ្វើរបង តបណ្ដាញទឹក ដាក់បណ្ដាញភ្លើង ដែលចំណាយការចំណាយប្រាក់អស់ចំនួន USD ៦០០០ (ប្រាំមួយពាន់ដុល្លារអាមេរិក)។

លុះមកដល់ឆ្នាំ២០១៤ ស្រាប់តែមានឈ្មោះ [redacted] ម៉េង និងប្រពន្ធឈ្មោះ [redacted] សោភា បានចេញមកអះអាងថា ដីដែលឈ្មោះ [redacted] វ៉ាន់ណេត ទិញពីឈ្មោះ [redacted] សុភី គឺជាកម្មសិទ្ធិរបស់ខ្លួន ដោយឈ្មោះ [redacted] ម៉េង និងប្រពន្ធឈ្មោះ [redacted] សោភា បានធ្វើការដាក់ពាក្យបណ្ដឹងទៅ [redacted] អភិបាល នៃគណៈអភិបាលខណ្ឌដង្កោ ដោយប្ដឹងពីឈ្មោះ [redacted] ចិន្តា និងប្រពន្ធឈ្មោះ [redacted] សុភី ដោយបានរំលោភយកដីរបស់ពួកគេដែលជាប្រភេទដីសង់ផ្ទះ ១កន្លែង ទំហំ ១៩៨,៥ ម² ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលពួកគេបានទិញពីឈ្មោះ [redacted] អេង តាមរយៈលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣៤៤/០៥ ប.ជ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ។ ហើយអាជ្ញាធរក៏បានទទួលស្គាល់ថាឈ្មោះ [redacted] ម៉េង និងប្រពន្ធឈ្មោះ [redacted] សោភា ពិតជាម្ចាស់កម្មសិទ្ធិលើដីនោះពិតប្រាកដមែន តាមរយៈកំណត់ហេតុស្ដីពីការសម្របសម្រួលទំនាស់ដីរវាងឈ្មោះ [redacted] ម៉េង និងឈ្មោះ [redacted] ចន្ថា នៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤។ ដោយមានការសម្របសម្រួលឈ្មោះ [redacted] ចិន្តា ក៏បានឯកភាព និងទទួលស្គាល់ថាដីនោះពិតជារបស់ឈ្មោះ [redacted] ម៉េង ពិតប្រាកដមែន ហើយធ្វើកំណត់ហេតុប្រគល់ទទួលដី រវាងឈ្មោះ [redacted] ចិន្តា និងប្រពន្ធឈ្មោះ [redacted] សុភី និងឈ្មោះ [redacted] ម៉េង និងប្រពន្ធឈ្មោះ [redacted] សោភា នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤។

បន្ទាប់មកឈ្មោះ [redacted] សុភី បានសន្យាធ្វើការសងប្រាក់ថ្លៃដីវិញ មកឱ្យឈ្មោះ [redacted] វ៉ាន់ណេត ដោយធ្វើកិច្ចព្រមព្រៀង ក្នុងការជ្រើសរើសយកក្រុមហ៊ុន អចលនទ្រព្យ BONNA REALTY GROUP (ប៊ុណ្ណា រៀលធី គ្រុប) ក្នុងការវាយតម្លៃជាក់ស្ដែងនៃទីផ្សារបច្ចុប្បន្ន លើដីមួយកន្លែងដែលមានទំហំ ១៩៨ ម២ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ដោយតាមការវាយតម្លៃរបស់ក្រុមហ៊ុន អចលនទ្រព្យ BONNA REALTY GROUP (ប៊ុណ្ណា រៀលធី គ្រុប) លេខ១៥០៦០៨១៩ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ បានបញ្ជាក់ថាដីដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ១០០១៩/១៣ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដែលមានទំហំ ១៩៨ម² ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ គឺមានតម្លៃ ២៥០ដុល្លារអាមេរិក ក្នុងមួយម៉ែត្រការ៉េ ហេតុដូច្នេះ ទឹកប្រាក់សរុបស្មើនឹង USD ៤៩៥០០ (បួនម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) ។ ប៉ុន្តែគិតចាប់ពីថ្ងៃនោះមករហូតមកដល់បច្ចុប្បន្នឈ្មោះ [redacted] សុភី បានគេចវេសមិនព្រមប្រគល់ប្រាក់មកឱ្យឈ្មោះ [redacted] វ៉ាន់ណេត វិញនោះទេ ទើបឈ្មោះ [redacted] វ៉ាន់ណេត ផ្ទេរសិទ្ធិជូនកូនក្ដីខ្ញុំបាទឈ្មោះ [redacted] ទីម ដាក់ពាក្យបណ្ដឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

## ២.អង្គច្បាប់

មាត្រា ៣៧៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា អំពើឆបោកគឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយប្រើឈ្មោះក្លែងដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភទលើឋានៈពិតប្រាកដ ឬ ដោយឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះដែលនាំឱ្យខូចប្រយោជន៍បុគ្គលនេះ ឬជាកាតព្វកិច្ច ឬជាការរួចផុតពីកាតព្វកិច្ច។

Scanned with CamScanner

មាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា: អំពើឆបោក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល។

ឈ្មោះ[redacted]សុភី បានអះអាងក្លែងបន្លំថាខ្លួនគឺជាម្ចាស់ដី០១កន្លែង ទំហំ១៩៨មឌ ស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ លក់ដីស្ថិតនៅភូមិ ខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើម្បីឱ្យឈ្មោះ ណាន វ៉ាន់ណេត មានការជឿជាក់ ក្នុងការទិញដីនោះពីឈ្មោះ [redacted]សុភី ដោយឯកភាពធ្វើកិច្ចសន្យាទិញលក់ដីនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣។ ប៉ុន្តែដីនោះមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ [redacted]សុភី នោះទេ គឺជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ម៉េង និងប្រពន្ធឈ្មោះ [redacted]សោភា ទៅវិញ ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ដីលេខ ៣៤៤/០៥ ប.ជ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ២០០៥។ ហើយអាជ្ញាធរក៏បានទទួលស្គាល់ថាឈ្មោះ [redacted]ម៉េង និងប្រពន្ធឈ្មោះ [redacted] សោភា ពិតជាម្ចាស់កម្មសិទ្ធិលើដីនោះពិតប្រាកដមែន តាមរយៈកំណត់ហេតុស្តីពីការសម្របសម្រួលទំនាស់ដីរបស់ឈ្មោះ [redacted]ម៉េង និងឈ្មោះ[redacted] ចន្ទា នៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១៤។

+សេចក្តីបំភ្លឺរបស់ឈ្មោះ[redacted]ចិន្តា នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ក៏បានទទួលស្គាល់ថាដីដែលជាកម្មវត្ថុនៃការទិញលក់ជាមួយឈ្មោះ [redacted] វ៉ាន់ណេត ពិតជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ម៉េង ប្រាកដមែន ហើយឈ្មោះ [redacted] ចិន្តា ក៏បានយល់ព្រមសងប្រាក់ថ្លៃដីមកឱ្យឈ្មោះ [redacted]វ៉ាន់ណេត ចំនួន USD ២៥០០០(ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ប៉ុន្តែឈ្មោះ ណាន វ៉ាន់ណេត មិនព្រមទទួលយក ព្រោះគាត់បានចំណាយចាក់ដី តបណ្តាយលូ ទឹក ភ្លើង អស់ប្រាក់ចំនួន USD ៦០០០(ប្រាំមួយពាន់ដុល្លារអាមេរិក) ហើយរយៈពេលដែលទិញដី មកដល់បច្ចុប្បន្នមានរយៈពេលច្រើនឆ្នាំមកហើយ តម្លៃដីក៏មិនត្រូវនៅដដែលនោះដែរ។ ចម្លើយរបស់ឈ្មោះ[redacted]សុភី នៅដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរគឺមានភាពប្រហាក់ប្រហែលគ្នា គឺឈ្មោះ [redacted] សុភី ពិតជាយល់ព្រមប្រគល់ដីដែលខ្លួនលួចមកលក់ឱ្យឈ្មោះ [redacted]វ៉ាន់ណេត ឱ្យទៅម្ចាស់ដើមគេវិញ នេះបញ្ជាក់ថាឈ្មោះ[redacted]សុភី មិនមានដីពិតប្រាកដនោះទេ។

+សាក្សីឈ្មោះ [redacted] ចិន្តា ដែលជាប្តីឈ្មោះ [redacted]សុភី បានឆ្លើយនៅដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរថា ដីដែលលក់ឱ្យឈ្មោះ [redacted] វ៉ាន់ណេត ខ្លួនបានផ្ទេរទៅឱ្យឈ្មោះ[redacted] ម៉េង រួចទៅហើយ ហើយខ្លួនសុំសងប្រាក់មកដើមបណ្តឹងវិញទៅតាមតម្លៃទីផ្សារជាក់ស្តែង។ ដោយផ្អែកទៅតាមកិច្ចព្រមព្រៀងរវាងឈ្មោះ [redacted] ណើម និងឈ្មោះ [redacted]ចិន្តា នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០១៥ បានបញ្ជាក់ថាភាគីឈ្មោះ[redacted]ចិន្តា យល់ព្រមសងប្រាក់ដើមវិញទៅតាមតម្លៃទីផ្សារ និងដោយផ្អែកទៅតាមការវាយតម្លៃរបស់ក្រុមហ៊ុនអចលនទ្រព្យ BONNA TEALTY GROUP (ប៊ុណ្ណា រៀលធី គ្រុប) លេខ១៥០៦០៨១៩ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥ បានបញ្ជាក់ថាដីដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ១០០១៩/១៣ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៣ ដែលមានទំហំ ១៩៨ មឌ ស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ គឺមានតម្លៃ ២៥០ដុល្លារអាមេរិក ក្នុងមួយម៉ែត្រការ៉េ ហេតុដូច្នេះ ទឹកប្រាក់សរុបស្មើនឹង ៤៩៥០០ (បួនម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) នៅក្នុងឆ្នាំ២០១៥។

Scanned with CamScanner

៣.<u>ភស្តុតាង</u>

- លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣។
- កិច្ចសន្យាលក់ដី ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣។
- កិច្ចព្រមព្រៀង ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥។
- កំណត់ហេតុសួរចម្លើយឈ្មោះ [redacted]ចិន្តា ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥។
- កំណត់ហេតុសួរចម្លើយឈ្មោះ [redacted] សាមឿន ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥។
- សេចក្តីបំភ្លឺ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។
- កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥។
- របាយការណ៍វាយតម្លៃអចលនវត្ថុលេខ១៥០៦០៩១៩ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥។
- របាយការណ៍វាយតម្លៃអចលនវត្ថុលេខ១៨០១០១០៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ ។

៤.<u>ការសន្និដ្ឋាន</u>

ផ្អែកតាមអង្គហេតុ អង្គច្បាប់ និងភស្តុតាង នៅក្នុងសំណុំរឿង បញ្ជាក់ឲ្យឃើញថា [redacted]សុភី ពិតជាបានប្រព្រឹត្តបទល្មើស ឧបាយកលទុច្ចរិតដោយបានអះអាងក្លែងបន្លំថាខ្លួនគឺជាម្ចាស់ដី០១កន្លែង ទំហំ ១៩៨ម៉ែ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ លក់ដីស្ថិតនៅភូមិ ទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ដោយហេតុថា ឈ្មោះ[redacted] សុភី មានស្មារតីយល់ដឹងគ្រប់គ្រាន់ទៅលើអំពើប្រព្រឹត្តរបស់ខ្លួនកាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៣ ក្នុងការលក់ដីមកឲ្យឈ្មោះ[redacted] វ៉ាន់ណេត ដែលទង្វើនេះបានធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ឈ្មោះ[redacted]វ៉ាន់ណេត។ ហើយ សាក្សីឈ្មោះ[redacted]ចិន្តា និងឈ្មោះ [redacted] សាមឿន សុទ្ធតែបានឆ្លើយដាក់បន្ទុកទៅលើឈ្មោះ[redacted]សុភី មិនត្រឹមតែប៉ុណ្ណោះ សាក្សីឈ្មោះ[redacted]ចិន្តា ដែលត្រូវជាប្តីរបស់ឈ្មោះ[redacted]សុភី ក៏បានបញ្ជាក់ថាប្រពន្ធរបស់ខ្លួនមិនមែនដីនោះទេ ថែមទាំងសន្យាសងប្រាក់ឲ្យឈ្មោះ[redacted]វ៉ាន់ណេត តាមការវាយតម្លៃរបស់ក្រុមហ៊ុនអចលនទ្រព្យ BONNA REALTY GROUP (ប៊ុណ្ណា រៀលធី គ្រុប)។ ហើយបច្ចុប្បន្ន តាមការវាយតម្លៃរបស់ក្រុមហ៊ុន អចលនទ្រព្យ BONNA REALTY GROUP (ប៊ុណ្ណា រៀលធី គ្រុប) លេខ១៨០១០១០៥ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ បានបញ្ជាក់ថាដីដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ១០០១៩/១៣ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ដែលមានទំហំ ១៩៨ ម៉ែ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ គឺមានតម្លៃ ៣២០ ដុល្លារអាមេរិក ក្នុងមួយម៉ែត្រការ៉េ ហេតុដូច្នេះ ទឹកប្រាក់សរុបស្មើរនឹង ៦៣,៣៦០ (ប្រាំមួយម៉ឺនបីពាន់បីរយហុកសិបដុល្លារអាមេរិក)។

៥.<u>សំណូមពរ</u>

- សូមផ្តន្ទាទោសឈ្មោះ [redacted] សុភី អោយបានធ្ងន់ធ្ងរតាមផ្លូវច្បាប់។
- សូមទាមទារប្រាក់ថ្លៃដីជាក់ស្តែងចំនួន USD៦៣,៣៦០(ប្រាំមួយម៉ឺនបីពាន់បីរយហុកសិបដុល្លារអាមេរិក) និងថ្លៃចាក់ដី តបណ្តាយលូ ទឹក ភ្លើងអស់ប្រាក់ចំនួន USD ៦០០០(ប្រាំមួយពាន់ដុល្លារអាមេរិក)។
- សូមទាមទារសំណងជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន USD ៤០០០(បួនពាន់ដុល្លារអាមេរិក)។

អាស្រ័យហេតុនេះ សូម លោកចៅក្រម មេត្តាទទួលសេចក្តីសន្និដ្ឋានខ្ញុំបាទដោយក្តីអនុគ្រោះ ។

Scanned with CamScanner

## សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានស្ដាប់ការសួរដេញដោលនាពេលសវនាការ និងពិនិត្យឯកសាររួចមកឃើញថា ពិតជាមានបទល្មើស ឆបោក ប្រព្រឹត្តដោយឈ្មោះ [redacted] សុភី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ មានភស្ដុតាងដាក់បន្ទុក ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សីបញ្ជាក់ ហេតុនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៥០ អ.យ.ក ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ទុកជាបានការដដែល និងសុំឲ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យឯកសារភស្ដុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ ពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## **សំអាងហេតុ**

១-តាមពាក្យបណ្ដឹងផ្ទាល់ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ឈ្មោះ [redacted]ទឹម តំណាងឲ្យឈ្មោះ [redacted] វ៉ាន់ណេត បានបញ្ជាក់ថា ពិតជាមានករណី ឆបោក ប្រព្រឹត្តនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១៣ ដែលបង្កឡើងដោយឈ្មោះ [redacted] សុភី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ប្រាកដមែន។

២-តុលាការបានទទួលសំណុំរឿងមកជំនុំជម្រះ ដែលមានជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ អាស្រី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៩៦ "ណ" ង.ង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ពីបទ ឆបោក បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ដែលចែងថា "អំពើឆបោក" ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ខែ(ប្រាំមួយខែ) ទៅ ៣ឆ្នាំ(បីឆ្នាំ) និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន)រៀល។

៣-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ អាស្រី បានឆ្លើយថា៖ ដីដែលខ្លួនបានលក់ទៅឲ្យឈ្មោះ [redacted] វ៉ាន់ណេត នេះ គឺជាដីរបស់ខ្លួនពិតប្រាកដមែន ដីនេះខ្លួនទិញពីឈ្មោះ [redacted]ទរិយា ក្នុងតម្លៃ ២០,០០០$(ពីរម៉ឺនដុល្លារអាមេរិក) ដោយមានឯកសារត្រឹមត្រូវ ហើយដីនេះខ្លួនកាន់កាប់អស់រយៈពេល ៨ឆ្នាំមកហើយ។ នៅក្នុងឆ្នាំ២០១៣ ខ្លួនបានលក់ដីនេះឲ្យទៅឈ្មោះ [redacted] វ៉ាន់ណេត ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងត្រឹមត្រូវ និងមានការបញ្ជាក់ពីអាជ្ញាធរសង្កាត់ទៀតផង ក្រោយលក់រួចមកអ្នកទិញបានចាក់ដី និងធ្វើរបងនៅលើដីនោះ ហើយក៏ពុំឃើញមាននរណាមកអះអាងថាដីនេះជាកម្មសិទ្ធិរបស់គេឡើយ ក្រោយមកឈ្មោះ [redacted] ម៉េង បានអះអាងថាដីនេះជាកម្មសិទ្ធិរបស់គេ ហើយអាជ្ញាធរខណ្ឌបានហៅខ្លួនមកចរចារប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted] ម៉េង តែមិនមានឯកសារណាមួយបញ្ជាក់ថាជាដីរបស់ឈ្មោះ [redacted] ម៉េង នោះទេ។



Scanned with CamScanner

អាជ្ញាធរខណ្ឌដង្កោបានឲ្យខ្លួនប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted] ម៉េង ព្រោះគេជាម្ចាស់ដើម [illegible] [redacted] ដែរ ពេលឮដូច្នេះ ខ្លួនក៏ភ័យខ្លាចក៏ប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted] ម៉េង [illegible]។ ការឆ្លើយរបស់ជនជាប់ចោទក្រោយតែជាការឆ្លើយដោះសារ [illegible]។

៤-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធីម [illegible]។ ឈ្មោះ [redacted] សុភី បាន លក់ដីមួយកន្លែងទំហំ ១៩៨ម៉ែត្រការ៉េ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ មកឲ្យខ្លួន ដោយ គាត់បានបង្ហាញឯកសារ និងអះអាងថាដីខាងលើនេះ គឺជាដីរបស់គាត់ ហើយអាជ្ញាធរក៏បានបញ្ជាក់ថា ដីនេះពិតជា ដីរបស់ឈ្មោះ [redacted] សុភី ប្រាកដមែន ។ ដោយមានការជឿទុកចិត្ត ខ្លួនក៏បានទិញដីនោះ ហើយឈ្មោះ [redacted] សុភី ក៏ បានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងកិច្ចសន្យា ព្រមទាំងលិខិតធានាអះអាងផ្សេងៗទៀតផង ។ ក្រោយមកពេល ឈ្មោះ [redacted] ម៉េង បានមកអះអាងថាដីដែលខ្លួនទិញនោះ គឺជាដីរបស់គេ ដោយបានបង្ហាញប័ណ្ណកម្មសិទ្ធិករលើដី នោះដែរ ហើយឈ្មោះ [redacted] សុភី ក៏បានព្រមព្រៀងទទួលស្គាល់ថា ដីដែលគាត់លក់មកឲ្យខ្លួននោះ ជាដីរបស់ឈ្មោះ [redacted] ម៉េង ហើយគាត់បានសន្យាថានឹងសងលុយថ្លៃទិញដីឲ្យមកខ្លួនវិញដែរ តែរហូតមកដល់ពេលនេះឈ្មោះ [redacted] សុភី បានគេចវេសមិនព្រមប្រគល់ប្រាក់ឲ្យមកខ្លួនវិញឡើយ ចំពោះដីនេះ ខ្លួនបានចាក់ដី ធ្វើរបង ដាក់ល្វ តបណ្តោ ញទឹក សរុបការចំណាយទាំងអស់ប្រហែល ៦,០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក)។

៥-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ចិន្តា បានឆ្លើយថា៖ ទាក់ទងនឹងរឿងលក់ដីមួយកន្លែងទំហំ ១៩៨ ម៉ែត្រការ៉េ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលដីនេះដើមឡើយ នៅក្នុងឆ្នាំ២០០៩ ឈ្មោះ [redacted] សុភី ហើយនៅក្នុងឆ្នាំ២០១៣ ហើយប្រពន្ធខ្លួនក៏ [redacted] ចរិយា បានផ្ទេរសិទ្ធិកាន់កាប់មកឲ្យប្រពន្ធខ្លួនឈ្មោះ [redacted] ក្រោយមកនៅឆ្នាំ២០១៩ ក៏កេន បានលក់ដីនោះឲ្យទៅឈ្មោះ [redacted] រ៉ាន់ណេត និងបានផ្ទេរសិទ្ធិត្រឹមត្រូវតាមច្បាប់ ចំពោះដីខាងលើ ឈ្មោះ [redacted] ម៉េង បានមកអះអាងថាដីនេះជាដីរបស់គាត់ ហើយប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ។ នេះ ខ្លួន និងប្រពន្ធខ្លួនសុខចិត្តសងប្រាក់ទៅឲ្យអ្នកទិញឈ្មោះ [redacted] រ៉ាន់ណេត វិញទៅតាមតម្លៃទីផ្សារជាក់ស្តែង។

៦-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សារឿន បានឆ្លើយថា៖ ឈ្មោះ [redacted] សុភី បានលក់ដីឲ្យទៅឈ្មោះ [redacted] រ៉ាន់ណេត និងបានធ្វើលិខិតផ្ទេរសិទ្ធិនៅចំពោះមុខខ្លួនដែលជាចៅសង្កាត់ដង្កោ។ ខ្លួនមិនបានចុះទៅពិនិត្យមើល ទីតាំងដីនេះទេ ប៉ុន្តែឃើញមានលិខិតកំណត់ហេតុមេភូមិ ភ្ជាប់មកជាមួយដោយផ្អែកលើលិខិតទាំងនេះ ខ្លួនក៏បាន បញ្ជាក់ទៅលើលិខិតផ្ទេរសិទ្ធិនោះតែម្តង។ ក្រោយមកក៏មានពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ម៉េង ចោទឈ្មោះ [redacted] សុភី ថាបានយកដីដែលជារបស់គាត់ទៅលក់ ហើយគាត់ក៏បានបង្ហាញលិខិតបញ្ជាក់កម្មសិទ្ធិលើដីនោះ ទើបខ្លួនដឹង ថាដីនោះមិនមែនជារបស់ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] សុភី ទេ ក្រោយមកខាងអាជ្ញាធរសង្កាត់ និងខណ្ឌដង្កោ បានហៅពួកគេមកសាកសួរ ហើយពួកគេក៏បានសារភាពថាច្រឡំដីរបស់ឈ្មោះ [redacted] ម៉េង ស្មានថាជាដីរបស់ខ្លួន ហើយគេក៏បានយល់ព្រមប្រគល់ដីនោះឲ្យទៅឈ្មោះ [redacted] ម៉េង កាន់កាប់វិញដែរ ហើយគេបានសន្យាថានឹងធានា ដោះស្រាយជាមួយអ្នកទិញបន្តទៀតឲ្យបានចប់សព្វគ្រប់។

Scanned with CamScanner

៧-តាមអំណានចម្លើយរបស់ជនជាប់ចោទ អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអំណានចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងជាឯកសារ មានភាពស៊ីសង្វាក់គ្នារកឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុភី ពិតជាបានប្រព្រឹត្តអំពើល្មើសប្រាកដមែន។

៨-អំពើរបស់ជនជាប់ចោទ ដែលបានប្រព្រឹត្ត គឺជាការប្រើល្បិច ឆបោក ដោយបានយកដីរបស់អ្នកដទៃមកធ្វើជារបស់ខ្លួន ហើយប្រើល្បិចលួងលោមជនរងគ្រោះឱ្យជឿទុកចិត្តទិញដីនោះ ដោយមានចេតនាទុច្ចរិតដែលចង់បានទ្រព្យរបស់អ្នកដទៃ ដោយខុសច្បាប់ ហើយអំពើនេះ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ , ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៩-ជនជាប់ចោទមានសមត្ថភាពយល់ដឹងខុសត្រូវពីអំពើប្រព្រឹត្តរបស់ខ្លួន និងអាចឱ្យទទួលខុសត្រូវចំពោះព្រហ្មទណ្ឌបាន។

១០-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ សំណងថ្លៃទិញដីចំនួន ៦៣,៣៦០$ (ប្រាំមួយម៉ឺនបីពាន់បីរយហុកសិបដុល្លារអាមេរិក) និងថ្លៃចាក់ដី តបណ្តាញលូ ទឹក ភ្លើង អស់ប្រាក់ចំនួន ៦,០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក) និងសំណងជំងឺចិត្ត ការខាតបង់ពេលវេលាចំនួន ៤,០០០$ (បួនពាន់ដុល្លារអាមេរិក)។ គប្បីតុលាការពិចារណាសម្រេច។

១១-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ប្តឹងសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៣៥០ អ.យ.ក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ទុកជាបានការដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់។

១២-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុភី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

១៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធីម តំណាងឱ្យឈ្មោះ [redacted]ាំណោត បានប្តឹងសុំទាមទារសំណងថ្លៃទិញដីជាក់ស្តែងចំនួន ៦៣,៣៦០$ (ប្រាំមួយម៉ឺនបីពាន់បីរយហុកសិបដុល្លារអាមេរិក) និងថ្លៃចាក់ដី តបណ្តាញលូ ទឹក ភ្លើង អស់ប្រាក់ចំនួន ៦,០០០$(ប្រាំមួយពាន់ដុល្លារអាមេរិក) និងសំណងជំងឺចិត្ត ការខាតបង់ពេលវេលាចំនួន ៤,០០០$ (បួនពាន់ដុល្លារអាមេរិក) គប្បីតុលាការពិចារណាសម្រេចតាមភាពជាក់ស្តែងនាពេលបច្ចុប្បន្ន។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើឈ្មោះ [redacted] សុភី ហៅ អាស្រី ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០១ (មួយ) ឆ្នាំ។

ពីបទ ឆបោក ប្រព្រឹត្តនៅចំណុចភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] សុភី ហៅ អាស្រី សងសំណងថ្លៃទិញទិញដីជាក់ស្តែងចំនួន ៦៣,៣៦០$ (ប្រាំមួយម៉ឺនបីពាន់បីរយហុកសិបដុល្លារអាមេរិក) និងថ្លៃចាក់ដី តបណ្តាញលូ ទឹក ភ្លើង ចំនួន ៦,០០០$(ប្រាំមួយពាន់ដុល្លារអាមេរិក

Scanned with CamScanner

ក) និងសំណងជំងឺចិត្ត ការខាតបង់ពេលវេលាចំនួន ៤,០០០$ (បួនពាន់ដុល្លារអាមេរិក) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទីម តំណាងឱ្យឈ្មោះ [redacted] រ៉ាត់ណេត ការទាមទារលើសពីនេះត្រូវលើកចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សុភី ហៅ អាស្រី និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ទីម និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨។

-គូភាគីមានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ មិថុនា ឆ្នាំ២០២១**

**ក្រឡាបញ្ជី**

[redacted]